ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ២ លេខ : ១២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC



ក ស វ

Work Activities

ប្រចាំខែ ធ្នូ ឆ្នាំ ២០០៩



# មាតិកាអត្ថបទ

កិច្ចប្រជុំពិភាក្សា របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងក្រសួងស្ថាប័នរាជរដ្ឋាភិបាល

**ល.រ ឈ្មោះអត្ថបទ**


១. សេចក្តីព្រាងអនុក្រឹត្យស្តីពី ការប្រែក្លាយមន្ទីរពេទ្យកុមារជាតិជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ........ ១

២. សេចក្តីព្រាងគោលនយោបាយស្តីពី ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ........ ២–៣

៣. សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ប្រព័ន្ធមតិកមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា ........ ៤–៥

៤. សេចក្តីព្រាងរបាយការណ៍ជាតិលើកទី៤ និងទី៥ ស្តីពី ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅប្រទេសកម្ពុជា ........ ៦

៥. ប្រជុំឡើងវិញលើសេចក្តីព្រាងច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ........ ៧

៦. ប្រជុំបន្តលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈឱសថការីកម្ពុជា ........ ៨

៧. ប្រជុំបន្តលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈស្ថាបត្យករកម្ពុជា ........ ៩

៨. សកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ........ ១០–១៣

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការប្រែក្លាយមន្ទីរពេទ្យកុមារជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

កាលពីថ្ងៃទី០៧ និងថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ ម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាពឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និងឯកឧត្តម **នាង ស៊ីថុង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី **ការប្រែក្លាយមន្ទីរពេទ្យកុមារជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងសុខាភិបាល សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។



ក្រសួងសុខាភិបាលបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមន្ទីរពេទ្យកុមារជាតិជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលបំណងកំណត់បទប្បញ្ញត្តិនានាចំពោះមន្ត្រីរាជការ និងបុគ្គលិកទាំងអស់ដែលបម្រើការនៅក្នុងមន្ទីរពេទ្យកុមារជាតិទាំងមូល ត្រូវគោរពករណីកិច្ចដើម្បីជាប្រយោជន៍លើកកម្ពស់សេវាសុខាភិបាលសម្រាប់ការចូលរួមចំណែកធ្វើឲ្យសម្រេចយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាល ពិសេសក្នុងវិស័យកំណែទម្រង់រដ្ឋបាលសាធារណៈសំដៅធ្វើយ៉ាងណាបម្រើប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង(១)។

អង្គប្រជុំបានឯកភាពពិនិត្យ ពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានធ្វើការកត់សម្គាល់ឃើញថា៖ សេចក្តីព្រាងអនុក្រឹត្យនេះមានលំនាំដូចអនុក្រឹត្យចំនួនពីរដែលបានចូលជាធរមានហើយ គឺអនុក្រឹត្យស្តីពី ការប្រែក្លាយមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត និងមន្ទីរពេទ្យព្រះកុសុមៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចនេះពុំមានអ្វីជាបញ្ហាធំដុំឡើយ គ្រាន់តែមានការកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួនដើម្បីឲ្យសេចក្តីព្រាងទាំងពីរនេះកាន់តែល្អប្រសើរ។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាលើសេចក្តីអនុក្រឹត្យនេះ៕

(១)អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមន្ទីរពេទ្យកុមារជាតិជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

## សេចក្តីព្រាងគោលនយោបាយស្តីពី

# ការគាំពារ និងអភិវឌ្ឍន៍កុមារតូច

កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០នាទី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាពឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) ឯកឧត្តម **អ៊ុក ឆាវិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងគោលនយោបាយស្តីពី **ការគាំពារ និងអភិវឌ្ឍន៍កុមារតូច** ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

កុមារតូចដែលចាប់ពីកកើតរហូតដល់អាយុក្រោម ៦ឆ្នាំ តែងមានការអភិវឌ្ឍលើផ្នែករាងកាយ និងស្មារតី ដែលជាតម្រូវការចាំបាច់សម្រាប់កុមារ។



កុមារមានការអភិវឌ្ឍឆាប់រហ័សផ្នែកខួរក្បាលនៅឆ្នាំដំបូងនៃជីវិតរបស់គេ។ បទពិសោធជាច្រើនបានបង្ហាញថា ជីវិតដំបូងរបស់កុមារត្រូវផ្តោតទៅលើការថែទាំ ការជួយទំនុកបម្រុងពីគ្រួសារ និងសង្គមឲ្យទទួលបាននូវសេវានានាដូចជា៖ អាហារូបត្ថម្ភ ការថែទាំសុខភាព ការផ្តល់ឱកាសរៀនសូត្រ ការការពារពីគ្រោះថ្នាក់ផ្សេងៗ។ល។ ការងារទាំងនេះអាចអនុវត្តបានជោគជ័យអាស្រ័យដោយមានគោលនយោបាយ និងមានការវិនិយោគដ៏សមស្របសម្រាប់កុមារតូចនិងគ្រួសារ។

រាជរដ្ឋាភិបាលតែងយល់អំពីសារៈសំខាន់នៃការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលជាគុណប្រយោជន៍ដល់អនាគតរបស់កុមារម្នាក់ៗក្នុងការក្លាយខ្លួនទៅជាសសរទ្រូងនៃប្រទេសជាតិ។ ការគាំពារ និងអភិវឌ្ឍន៍តូច ជាការងារអទិភាព ហើយជាផ្នែកមួយខានមិនបាននៃការអប់រំសម្រាប់ទាំងអស់គ្នា ហើយក៏ជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលផងដែរ។

រាជរដ្ឋាភិបាលបានលើកស្ទួយសុខុមាលភាពប្រជាជនទូទៅពិសេសប្រជាជនក្រីក្រស្ត្រី និងកុមារ។ ជាលទ្ធផលអត្រាស្លាប់របស់ទារកបានថយចុះពី ៩៥ នៅឆ្នាំ២០០០ មកត្រឹម ៦៦ ក្នុង ១០០០កំណើត ក្នុងឆ្នាំ២០០៥។ អត្រាស្លាប់របស់កុមារក្រោមអាយុ ៥ឆ្នាំ ក៏បានធ្លាក់ចុះគួរគត់សម្គាល់។ ប៉ុន្តែអត្រាមរណៈរបស់មាតាពេលសម្រាលកូននៅខ្ពស់នៅឡើយគឺ ៤៧២ ក្នុងកំណើតរស់ ១០០.០០០នាក់។ ក្នុងឆ្នាំ២០០៥ ស្ត្រីមានផ្ទៃពោះលើសពី ៦៩% បានទទួលការថែទាំសុខភាពមួយដងយ៉ាងតិចមុនពេលសម្រាលកូន។

ភស្តុតាងជាច្រើនបានឲ្យដឹងថា កុមារដែលមានការខ្វះអាហារូបត្ថម្ភ ខ្វះទម្ងន់ និងមានសុខភាពមិនល្អ ជាមូលហេតុធ្វើឲ្យគេគ្មានសមត្ថភាពរៀនសូត្របានល្អ។ អត្រាចូលរៀនរបស់កុមារតូចបានកើនឡើងពី ១០,៨% ក្នុងឆ្នាំ២០០៥ ទៅ ១៥,៦% ក្នុងឆ្នាំ២០០៨។ ការសិក្សាស្រាវជ្រាវជាច្រើនបានឲ្យដឹងថា កុមារដែលបានឆ្លងកាត់ថ្នាក់មត្តេយ្យ តែងតែចូលរៀនបាននៅសាលាបឋមសិក្សានៅអាយុ ៦ឆ្នាំ ហើយភាគច្រើនរៀនចប់បឋមសិក្សាដោយពុំមានការត្រួតថ្នាក់ និងបោះបង់ការសិក្សា។

រដ្ឋធម្មនុញ្ញ ច្បាប់ និងគោលនយោបាយនៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់អំពីការយកចិត្តទុកដាក់លើការគាំពារ ថែទាំ និងអប់រំកុមារជាអាទិ៍ មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញបានចែងថា៖ "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឲ្យរាំងស្ទះដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំ ឲ្យអន្តរាយដល់សុខុមាលភាពរបស់កុមារ "។

សេចក្តីព្រាងគោលនយោបាយស្តីពីការគាំពារ និងអភិវឌ្ឍន៍ កុមារតូចមានចក្ខុវិស័យ "កុមារតូចទាំងអស់ចាប់ពីកើតរហូតដល់អាយុក្រោម ៦ឆ្នាំ ត្រូវទទួលបានសេវាគាំពារ និងអភិវឌ្ឍន៍ ជាពិសេសកុមាររងគ្រោះ កុមារងាយរងគ្រោះ និងក្រខ្សត់ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា " និងមានលទ្ធផលរំពឹងទុក ដូចតទៅ៖

-ស្ត្រីទាំងអស់ទទួលបាននូវសេវាថែទាំ និងសេវាអប់រំសុខភាព ព្រមទាំងអាហារូបត្ថម្ភនៅពេលមានផ្ទៃពោះ

-កុមារតូចទាំងអស់ទទួលបានការចុះបញ្ជីកំណើត ការថែទាំ ការពិនិត្យសុខភាពជាប្រចាំ ថ្នាំបង្ការគ្រប់គ្រាន់ ទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ និងទទួលបានការហាត់រៀនពីដំបូង

-កុមារតូចទាំងអស់មានលក្ខណៈត្រៀមជាស្រេចដើម្បីចូលរៀនថ្នាក់ទី១ នៅអាយុ ៦ឆ្នាំ

-មានបុគ្គលិកបច្ចេកទេស អ្នកថែទាំកុមារ និងមាតាបិតា មានចំណេះដឹងគ្រប់គ្រាន់លើការគាំពារ និងអភិវឌ្ឍន៍កុមារតូច

-គ្រប់ក្រសួងពាក់ព័ន្ធទាំងអស់ធ្វើកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងការគាំពារ និងអភិវឌ្ឍន៍កុមារតូច

-កុមារតូចចាប់ពីពេលប្រសូត្ររហូតដល់ចូលរៀនមានការរីកចម្រើនផ្នែករាងកាយ ចំណេះដឹង ប្រាជ្ញា និងអារម្មណ៍នៅតាមផ្ទះរបស់ខ្លួន ព្រមទាំងតាមមណ្ឌលដែលផ្តល់សេវាសុខភាព អាហារូបត្ថម្ភ និងអប់រំប្រកបដោយគុណភាព និងនិរន្តភាព[១]។

អង្គប្រជុំបានឯកភាពពិនិត្យ ពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានធ្វើការកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួនដើម្បីឲ្យសេចក្តីព្រាងគោលនយោបាយនេះកាន់តែល្អប្រសើរ។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងគោលនយោបាយនេះ៕

[១]អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុលើសេចក្តីព្រាងគោលនយោបាយស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច។

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ប្រព័ន្ធមតិកមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា

កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០នាទី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) ឯកឧត្តម **អ៊ុក ឝូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី **ប្រព័ន្ធមតិកមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។



ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមតិកមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា ដោយមានមូលហេតុសំខាន់ៗដូចខាងក្រោមនេះ៖

ប្រព័ន្ធមតិកមនុស្សរស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិតជាមានសារៈសំខាន់ណាស់ដល់ការថែរក្សា និងអភិវឌ្ឍន៍បេតិកភណ្ឌវប្បធម៌អរូបីរបស់ជាតិឲ្យបានគង់វង្ស និងរីកចម្រើនទៅអនាគត ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល។ តាមការវិវឌ្ឍរបស់សង្គមមនុស្ស គ្រប់សមិទ្ធផលទាំងអស់ ដែលមនុស្សបានបង្កើត គឺជាសម្បត្តិវប្បធម៌។ ភាពផ្សេងគ្នានៃវប្បធម៌ក្នុងពិភពលោកត្រូវបានចាត់ទុកជាចំណេះដឹងជាប្រពៃណី និងជាធនធានដែលមានគុណប្រយោជន៍ដ៏សំខាន់ដល់ការអភិវឌ្ឍសង្គមប្រកបដោយចីរភាព។ មតិកវប្បធម៌ទាំងនេះចាំបាច់ត្រូវការពារ និងលើកស្ទួយឲ្យបានសមស្រប និងទាន់ពេលវេលា។

អនុសញ្ញាអន្តរជាតិបានកំណត់ថា បេតិកភណ្ឌវប្បធម៌អរូបីគឺជាមូលដ្ឋានគ្រឹះនៃវប្បធម៌ចម្រុះ និងជាការធានាកិច្ចអភិវឌ្ឍប្រកបដោយចីរភាពរបស់សង្គម ដូចបានគូសបញ្ជាក់ក្នុងអនុសាសន៍របស់អង្គការយូណេស្កូ ស្តីពីការការពារវប្បធម៌ ប្រពៃណី និងប្រជាជន នាឆ្នាំ១៩៨៩ និងសេចក្តីថ្លែងការណ៍ជាសកលស្តីពីភាពប្លែកគ្នារវាងវប្បធម៌ នាឆ្នាំ២០០១ នោះដែរ។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់ជាមហាប្រទេសមានអរិយធម៌ដ៏រុងរឿងក្នុងសម័យបុរាណ ដែលបានបន្សល់ទុកនូវកេរដំណែលបេតិកភណ្ឌវប្បធម៌ដ៏ច្រើនសន្ធឹកសន្ធាប់ពាសពេញផ្ទៃប្រទេស ត្រូវបានឆ្លងកាត់សម័យកាលដ៏មហាវិនាសកម្ម ដែលបានបំផ្លាញស្ទើរអស់គ្មានសល់នូវអ្នកប្រាជ្ញ បណ្ឌិត គ្រូនតម្រាល និងធនាន

មនុស្សប្រកបដោយទេពកោសល្យ។ ពេលបច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា ត្រូវប្រឈមនឹងចរន្តសាលកភាវូបណីយកម្ម ដែលអាចគំរាមទៅលើបេតិកភណ្ឌវប្បធម៌អរូបីដោយសារការខ្វះខាតមធ្យោបាយសម្រាប់ការពារ។

ភាពស្រុតចុះមួយទៀតនៃអាយុកាលសិល្បករចាស់ទុំ ដែលមានវ័យកាន់តែជរាបន្តបន្ទាប់គ្នា បើគ្មានការលើកស្ទួយឲ្យទាន់ពេលវេលា អាចនឹងធ្វើឲ្យមានការបាត់បង់នូវចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសទាំងអស់របស់ដូនតា ដោយសារយើងពុំទាន់បានរៀបចំឲ្យមានជាចរន្តបន្តវេនទៅជំនាន់ក្រោយ ដែលការបាត់បង់នេះ គឺជាការបាត់បង់នូវព្រលឹងដែលជាអត្តសញ្ញាណជាតិ និងជាមូលដ្ឋានគ្រឹះនៃវប្បធម៌ អរិយធម៌ថែមទៀត។

ដូច្នេះប្រព័ន្ធមតិកមនុស្សរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសារសំខាន់ណាស់ដល់ការថែរក្សា ការផ្ទេរ ចំណេះដឹង ការបន្តវេន និងការអភិវឌ្ឍវប្បធម៌ជាតិឲ្យបានគង់វង្សទៅអនាគត(១)។

ដោយយល់ឃើញពីសារសំខាន់ អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងផុលផុស ហើយបានសម្រេចកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួន ដើម្បីធ្វើឲ្យសេចក្តីព្រាងព្រះរាជក្រឹត្យនេះ កាន់តែល្អប្រសើរថែមទៀត។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យនេះ៕



(១)អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមតិកមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា។

## សេចក្ដីព្រាងរបាយការណ៍ជាតិលើកទី៤ និងលើកទី៥ ស្ដីពី

# ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅប្រទេសកម្ពុជា

កាលពីថ្ងៃទី២៤, ២៥ ខែធ្នូ ឆ្នាំ២០០៩ ម៉ោង ១៥:០០នាទី និងវេលាម៉ោង ៨:៣០នាទី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាពឯកឧត្តម **ឃឹម ឈុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) និងឯកឧត្តម **អ៊ី ប៊ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្ដីព្រាងរបាយការណ៍ជាតិលើកទី៤ និងលើកទី៥ ស្ដីពីការអនុវត្តអនុសញ្ញាអន្តរជាតិស្ដីពី **ការលុបបំបាត់រាល់ទម្រង់នៃ ការរើសអើងប្រឆាំងនឹងនារីភេទ នៅប្រទេសកម្ពុជា** ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួងកិច្ចការនារី សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី។



ក្រសួងកិច្ចការនារីបានរៀបចំ សេចក្ដីព្រាងរបាយការណ៍ជាតិលើកទី៤ និងលើកទី៥ ស្ដីពីការអនុវត្តអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃ ការរើសអើងប្រឆាំងនឹងនារីភេទនៅប្រទេសកម្ពុជា ក្នុងគោលបំណងដូចខាងក្រោមនេះ៖

-បញ្ជាក់ពីលទ្ធផលនៃការអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។

-អនុលោមទៅតាមមាត្រា១៨នៃអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់ការរើសអើង ប្រឆាំងនឹងស្ត្រីភេទដែលប្រទេសកម្ពុជា ជារដ្ឋភាគីមានកាតព្វកិច្ចរៀបចំរបាយការជាតិ តាមកាលកំណត់លើកទី៤ និងលើកទី៥ ដែលទាក់ទងនឹងអនុសញ្ញានេះ។

-ផ្ញើរបាយការណ៍ជាតិតាមការកំណត់លើកទី៤ និងលើកទី៥ នេះ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីគណៈកម្មាធិការពិនិត្យរបាយការលើវិធានការខាងនីតិកម្មតុលាការរដ្ឋបាល ឬវិធានការផ្សេងៗដែលបានអនុម័ត ផ្ដល់អនុភាពដល់បទប្បញ្ញត្តិនៃអនុសញ្ញាព្រមទាំងការរីកចម្រើន ដែលសម្រេចបានក្រោយពីបានសេចក្ដីសម្រេច "ឯកភាព " ពីរាជរដ្ឋាភិបាល(១)។

អង្គប្រជុំបានឯកភាពពិនិត្យ ពិភាក្សាលើសេចក្ដីព្រាងឯកសារនេះ ហើយបានធ្វើការកែសម្រួលខ្លឹមសារមួយចំនួន ដើម្បីឲ្យសេចក្ដីព្រាងរបាយការជាតិនេះត្រឹមត្រូវតាមស្ថានភាពបច្ចុប្បន្ន។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាជាបណ្ដោះអាសន្ននៅមាត្រាទី៤៕

(១)អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុលើសេចក្ដីព្រាងរបាយការណ៍ជាតិលើកទី៤ និងទី៥ ស្ដីពីការអនុវត្តអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅប្រទេសកម្ពុជា។

## ប្រជុំឡើងវិញសេចក្តីព្រាងច្បាប់ស្តីពី

# នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាពឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) និងឯកឧត្តម **អ៊ី ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាឡើងវិញលើសេចក្តីព្រាងច្បាប់ស្តីពី **នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងយុត្តិធម៌ សមាជិកអគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។





គួររំលឹកថា សេចក្តីព្រាងច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បានដាក់ឆ្លងកិច្ចប្រជុំទី១ កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ហើយជាលទ្ធផលនាពេលនោះ ក្រសួងយុត្តិធម៌ដែលជាក្រសួងសាមី បានស្នើដកសេចក្តីព្រាងច្បាប់នេះទៅវិញ ដើម្បីធ្វើការពិចារណាកែសម្រួលតាមស្មារតីរបស់អង្គប្រជុំ។

អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងផុលផុសលើសេចក្តីព្រាងច្បាប់កែសម្រួលថ្មីនេះ ហើយបានសម្រេចកែសម្រួលខ្លឹមសារខ្លះៗ ដើម្បីធ្វើឲ្យសេចក្តីព្រាងច្បាប់នេះ កាន់តែល្អប្រសើរ និងករណីខ្លះទៀតដែលអង្គប្រជុំបានលើកឡើង ក្រសួងសាមីនឹងយកទៅពិចារណា។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ៕

## ប្រជុំពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតគណៈឱសថការីកម្ពុជា

កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០នាទី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) ឯកឧត្តម **អ៊ុក ឥទ្ធិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សា បន្តលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈឱសថការីកម្ពុជា ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងសុខាភិបាល សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំលឹកថា សេចក្តីព្រាងព្រះរាជក្រឹត្យនេះធ្លាប់បានដាក់ ឆ្លងប្រជុំទី១ កាលពីថ្ងៃទី០៩, ១០ ខែមិថុនា ឆ្នាំ២០០៩ ហើយជាលទ្ធផលគឺបានបង្កើតក្រុមការងារចង្អៀតមួយដើម្បីរៀបចំកែសម្រួលឡើងវិញ។ សេចក្តីព្រាងព្រះរាជក្រឹត្យកែសម្រួលថ្មី បានដាក់ឆ្លងកិច្ចប្រជុំទី១ ម្តងទៀតកាលពីថ្ងៃទី០៨, ១០ ខែកញ្ញា ឆ្នាំ២០០៩ ហើយជាលទ្ធផល អង្គប្រជុំនៅមិនទាន់បានសម្រេចនៅឡើយ។ ទើបនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ អង្គប្រជុំទី១ បានសម្រេចយកសេចក្តីព្រាងដំបូងមកពិនិត្យ ពិភាក្សា នឹងបានកែសម្រួលឲ្យបានដូចព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈទន្តពេទ្យ ស្របទាំងសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី កាលពីឆ្នាំ២០០៥។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យនេះ៕

## ប្រជុំពិនិត្យលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតគណៈស្ថាបត្យករកម្ពុជា



កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) និង ឯកឧត្តម **សំ សុខផល** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាបន្តលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី **ការបង្កើតគណៈស្ថាបត្យករកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំលឹកផងដែរថា សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា បានដាក់ឆ្លងកិច្ចប្រជុំទី១ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយជាលទ្ធផល អង្គប្រជុំទី១ បានស្នើឲ្យក្រសួងសាមីយកសេចក្តីព្រាងព្រះរាជក្រឹត្យនេះទៅរៀបចំឡើងវិញ រួចហើយដាក់ប្រជុំម្តងទៀតនៅពេលក្រោយ។

អង្គប្រជុំបានពិភាក្សាគ្នា ហើយបានកត់សម្គាល់ថា ខ្លឹមសារនៃសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ដែលតម្រូវឲ្យស្ថាបត្យករត្រូវចុះបញ្ជីដើម្បីអាចប្រកបមុខរបរនេះបានមានជាអាទិ៍ មាត្រា៣ មាត្រា៤ មាត្រា២១ មាត្រា២២ មាត្រា២៣ និងមាត្រា៣៤ និងចំណងជើងនៃជំពូកមួយចំនួនមានខ្លឹមសារផ្ទុយនឹងមាត្រា១៥ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ឆ្នាំ១៩៩៤ ដែលមិនបានតម្រូវដូច្នេះ។

អង្គប្រជុំបានស្នើឲ្យមានជំរើសពីរ៖

១-ធ្វើវិសោធកម្មច្បាប់ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤។

២-កែសម្រួលសេចក្តីព្រាងព្រះរាជក្រឹត្យនេះ កុំឲ្យមានខ្លឹមសារផ្ទុយនឹងច្បាប់ខាងលើនេះ។ ប៉ុន្តែអង្គប្រជុំក៏មានការបារម្ភផងដែរ ពីភាពមិនអាចអនុវត្តបានដោយជោគជ័យនៃជំរើសនេះនាពេលអនាគត។

ជាលទ្ធផល សាមីក្រសួងស្នើយកជំរើសទី២ ដើម្បីធ្វើការកែសម្រួលឡើងវិញ៕



# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម ឃឹម ណារុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ ធ្នូ ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២.១២.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីមីទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៣១ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នៅសាលសន្និសីទចតុមុខ។ |
| ២ | ០៣.១២.០៩ | ចូលរួមជាកិត្តិយសក្នុងទិវាជនពិការកម្ពុជាលើកទី១១ និងទិវាជនពិការអន្តរជាតិខួបលើកទី២៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅមជ្ឈមណ្ឌលវប្បធម៌ សម្តេចហ៊ុនសែន នាវិទ្យាស្ថានជាតិអប់រំ។ |
| ៣ | ០៤.១២.០៩ | ចូលរួមក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជន នៃអគារសហកម្មសិទ្ធិដល់ជនបរទេស។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ។<br>៣-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។<br>៤-បញ្ហាផ្សេងៗ:សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ:<br>៤.១-កិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មទំនិញអាស៊ានសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន។<br>៤.២-អនុសញ្ញាអាស៊ានស្តីពី ការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម។ |
| ៤ | ០៨.១២.០៩<br>(ល្ងាច) | ប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៨.១២.០៩ | (ល្ងាច) ជួបប្រជុំពិភាក្សាជាមួយបារាំង។ |
| ៦ | ០៩.១២.០៩ | ប្រជុំប្រចាំខែជាមួយ Airport Committee នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៩ ,១០.១២.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីជូន និងទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ អញ្ជើញទៅបំពេញទស្សនកិច្ចការងារ និងចូលរួមបើកការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ២៥ នៅទីក្រុងវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ |
| ៨ | ១១.១២.០៩ | ចូលរួមក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ។<br>២-បញ្ហាផ្សេងៗ |
| ៩ | ១៥.១២.០៩ | ចូលរួមក្នុងសម័យប្រជុំពេញអង្គលើកទី ១៦ នៃគណៈកម្មការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ " CIC " ក្រោមអធិបតីភាពរបស់សហប្រធានទាំងពីរ (ឯកអគ្គរដ្ឋទូតប្រទេសបារាំង និងឯកអគ្គរាជទូតប្រទេសជប៉ុន) និងគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា នៅខេត្តសៀមរាប-សណ្ឋាគារសុខាអង្គរ។ |
| ១០ | ២២.១២.០៩<br>(ព្រឹក) | ចូលរួមក្នុងពិធីសម្ពោធជានិមិត្តរូបរបស់វិទ្យាស្ថាន Khong Zi ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ១១ | ២២.១២.០៩<br>(ល្ងាច) | ចូលរួមក្នុងពិធីបិទសិក្ខាសាលាស្តីពី " ការប្រយុទ្ធទប់ស្កាត់អំពើចោរកម្ម ការចរាចរ និងការជួញដូរវត្ថុបុរាណខុសច្បាប់ " រៀបចំឡើងដោយគណៈកម្មាធិការជាតិយូណេស្កូកម្ពុជា ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិយូណេស្កូកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| ១២ | ២៣.១២.០៩<br>(ព្រឹក) | ចូលរួមជាអធិបតីក្នុងពិធីប្រកាស និងផ្សព្វផ្សាយអំពី " កាប្រព្រឹត្តិទៅរបស់គណៈវិស្វករកម្ពុជា " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា នៅសណ្ឋាគារណាហ្គាវើល។ |
| ១៣ | ២៣.១២.០៩ | (ល្ងាច) ប្រជុំជាមួយគណៈកម្មការដេញថ្លៃការសាងសង់សារមន្ទីរវាយនភ័ណ្ឌប្រពៃណីអាស៊ាន។ |
| ១៤ | ២៨.១២.០៩ | ប្រជុំជាមួយក្រុមការងារមជ្ឈមណ្ឌលរដ្ឋបាលប្រមូលផ្តុំខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ៣០.១២.០៩<br>(ព្រឹក) | ប្រជុំពុនិត្យ និងពិភាក្សាការងារកែប្លង់ស្ថាបត្យកម្ម នៃការសាងសង់ទីស្នាក់ការអាជ្ញាធរអប្សរា ខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ៣០.១២.០៩<br>(ព្រឹក) | ប្រជុំពិភាក្សាលើការងារសាងសង់ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់អភិវឌ្ឍន៍រុនតាឯកខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ ឯកឧត្តម គឹម សយសាម៉ាឡែន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ ធ្នូ ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២.១២.០៩ | ប្រជុំក្រុម១ ECOSOCC ស្តីពីការរៀបចំការសិក្សាស្រាវជ្រាវ។ |
| ២ | ០៨.១២.០៩ (ល្ងាច) | ប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៧.១២.០៩ | ប្រជុំការធ្វើបទបង្ហាញពាក់ព័ន្ធនឹងការស្ទង់មតិសាធារណៈរបស់ប្រជាជនកម្ពុជា ដោយអង្គការ IRI ។ |
| ៤ | ៣០.១២.០៩ | ចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៃសាកលវិទ្យាល័យបៀលប្រាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានជាតិអប់រំ។ |

## សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ប៉ិច ឈុន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ ធ្នូ ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ២៣.១២.០៩ (ព្រឹក) | ចូលរួមជាអធិបតីក្នុងពិធីប្រកាស និងផ្សព្វផ្សាយអំពី " កាប្រព្រឹត្តិទៅរបស់គណៈវិស្វករកម្ពុជា " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ៣០.១២.០៩ | ចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៃសាកលវិទ្យាល័យបៀលប្រាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានជាតិអប់រំ។ |

## សកម្មភាពដទៃទៀតរបស់ ឯកឧត្តម យឹម ណុលសន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ ធ្នូ ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ២២.១២.០៩ (ព្រឹក) | ចូលរួមក្នុងពិធីសម្ពោធជានិមិត្តរូបរបស់វិទ្យាស្ថាន Khong Zi ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ២ | ២២.១២.០៩ (ល្ងាច) | ចូលរួមក្នុងពិធីបិទសិក្ខាសាលាស្តីពី " ការប្រយុទ្ធទប់ស្កាត់អំពើចោរកម្ម ការចរាចរ និងការជួញដូរវត្ថុបុរាណខុសច្បាប់ " រៀបចំឡើងដោយគណៈកម្មាធិការជាតិយូណេស្កូកម្ពុជា ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៣.១២.០៩ (ព្រឹក) | ចូលរួមជាអធិបតីក្នុងពិធីប្រកាស និងផ្សព្វផ្សាយអំពី " កាប្រព្រឹត្តិទៅរបស់គណៈវិស្វករកម្ពុជា " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ៣០.១២.០៩ | ចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៃសាកលវិទ្យាល័យបៀលប្រាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានជាតិអប់រំ។ |

# សកម្មភាពផ្សេងៗទៀតរបស់ឯកឧត្តម សមាជិក_សមាជិកា ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ ធ្នូ ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១ | ៣០.១១.០៩ ដល់ ០៤.១២.០៩ | ឯកឧត្តម **ឆាយ ខុម** ចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពី ការរៀបចំច្បាប់គ្រប់គ្រងសារធាតុគីមី នៅសណ្ឋាគារអប្សរាអង្គរខេត្តសៀមរាប។ |
| ២ | ២២.១២.០៩ (ព្រឹក) | ឯកឧត្តម **កាំង តុងហ៊ាង** និងឯកឧត្តម **ឡេង ស្រេង** ចូលរួមក្នុងពិធីសម្ពោធជានិមិត្តរូបរបស់វិទ្យាស្ថាន Khong Zi ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ៣ | ២២.១២.០៩ (ល្ងាច) | ឯកឧត្តម **កាំង តុងហ៊ាង** និងឯកឧត្តម **ឡេង ស្រេង** ចូលរួមក្នុងពិធីបិទសិក្ខាសាលាស្តីពី " ការប្រយុទ្ធទប់ស្កាត់អំពើចោរកម្ម ការចរាចរ និងការជួញដូរវត្ថុបុរាណខុសច្បាប់ " រៀបចំឡើងដោយគណៈកម្មាធិការជាតិយូណេស្កូកម្ពុជា ជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិយូណេស្កូកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| ៤ | ២៣.១២.០៩ | ឯកឧត្តម **កាំង តុងហ៊ាង** និងឯកឧត្តម **ឡេង ស្រេង** ចូលរួមជាអធិបតីក្នុងពិធីប្រកាស និងផ្សព្វផ្សាយអំពី " កាប្រព្រឹត្តិទៅរបស់គណៈវិស្វករកម្ពុជា "ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា នៅសណ្ឋាគារណាហ្គាវើល។ |
| ៥ | ១៨_២៥.១២.០៩ | ឯកឧត្តម **កាំង តុងហ៊ាង** ជួយពិនិត្យសិក្សា និងរៀបចំឡើងវិញនូវសេចក្តីព្រាងកិច្ចសន្យាស្តីពីសហាជីពឥណទានរយៈពេលខ្លីដែលមានទឹកប្រាក់ ២៣.០០០.០០០ USD របស់ធនាគារជាតិអភិវឌ្ឍន៍ជនបទ (ដោយបានទទួលការឯកភាពពីឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន ECOSOCC)។ |
| ៦ | ៣០.១២.០៩ | ឯកឧត្តម **ឆាយ ខុម** និងឯកឧត្តម **ឡេង ស្រេង** ចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិតថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតនៃសាកលវិទ្យាល័យបៀលប្រាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៧ | ៣១.១២.០៩ | ឯកឧត្តម **ឆាយ ខុម** និងឯកឧត្តម **ឡេង ស្រេង** ចូលរួមប្រជុំអន្តរក្រសួងស្តីពី ប្រព័ន្ធមតិកមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា។ |

# ព្រឹត្តិបត្រព័ត៌មាន

| | |
|---|---|
| naykRKbRKgTeTA 3 | ឯកឧត្តម គឹម សយសាម៉ាឡែន GnRbFan k>s>v> |
| nBnnayk 3 | ឯកឧត្តម វង្ស សំអាង GKe l xaFkar k>s>v> |
| nBnGtbT 3 | ឯកឧត្តម អេង វត្ថមុនី GKe l xaFkarrg k>s>v> |
| beckeTskBüTr ngcatEcgTeTA3 | លោក សយ វាស្នា RbFankarya l y k>s>v> |
| ykBtman ngrbft 3 | លោក ហេង សុភះបញ្ញា RbFankarya l y k>s>v> |
| TnakTng nge)aHBmpSay 3 | លោក ម៉ក់ ឆារ៉ា CnykareTsrdm®nl RbFan k>s>v> |




ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទ ០២៣ ២១១ ៩៤៣ , ០១៦ ៣០៧ ៣៣០

ទូរសារ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in